# កាត់បន្ថយភាពក្រីក្រតាមរយៈសកម្មភាពគាំទ្រអង្គការកសិករ

## ចំណាយតិចចំណូលច្រើន



ក្រៅពីមុខរបរធ្វើស្រែ កសិករនៅក្នុងខេត្តព្រៃវែង តែងស្វែងរក បង្កើតនូវការងារជាច្រើនទៀត ដើម្បីរកប្រាក់ចំណូលបន្ថែមក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ។ ជាក់ស្តែងកសិករ រ៉ែន សារ៉ែម មានអាយុ ៤៧ឆ្នាំ រស់នៅភូមិស្នួល ឃុំស្ពឺ 'ក' ស្រុកបាភ្នំ ខេត្តព្រៃវែង មានការមមាញឹកជាមួយនឹងការងារកសិកម្ម ដូចជាការធ្វើស្រែវស្សា ចិញ្ចឹមសត្វ... ។ ក្នុងចំណោមការងារបន្ថែមនោះគាត់មានការជាប់អារម្មណ៍ទៅលើ ការចិញ្ចឹមមាន់ ជាងគេហើយគាត់ក៏បានមានប្រសាសន៍ថា:



### - កាលពីមុន

គាត់ក៏មានចិញ្ចឹមមាន់ដែរ តែការចិញ្ចឹមនោះគឺ ធ្វើទៅតាមតែទំលាប់តៗគ្នា ឬយថាផល ។ ការឲ្យចំណីមិនបានទៀងទាត់ គ្មានទ្រុងមាន់ និងក៏មិនបានធ្វើអនាម័យកន្លែងមាន់នៅដែរ ។

### - ក្រោយមក

នៅខែ តុលា ឆ្នាំ ២០០៨ អង្គការកសិករសាមគ្គីមានរិទ្ធ ភូមិស្នួល ឃុំស្ពឺ 'ក' ស្រុកបាភ្នំ ខេត្តព្រៃវែង បានរៀបចំប្រជុំបង្កើតសកម្មភាពថ្មី គឺការចងក្រងក្រុមចិញ្ចឹមមាន់ ដោយមានការជួយសម្របសម្រួលពីបុគ្គលិកគម្រោងដៃគូនៃអង្គការក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន ។ លោកពូក៏បានស្ម័គ្រចិត្តចូលរួមសកម្មភាពនោះ ហើយបន្ទាប់មកគាត់បានទទួលការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ និងទទួលបានមេមាន់ចំនួន ៤ក្បាល និងមាន់ឈ្មោលចំនួន ១ក្បាល ពីគម្រោងដៃគូ ។ ពេលនោះលោកពូបានកែប្រែពីការចិញ្ចឹមមាន់តាមទំលាប់មកជាការចិញ្ចឹមតាមលក្ខណៈបច្ចេកទេសខ្លះៗដូចខាងក្រោម:

## ក. ទ្រុងមាន់



គាត់បានជ្រើសរើសទីតាំងដែលមានដីទួលខ្ពស់ មិនលិចទឹក ដីរាបស្មើ សម្រាប់សាងសង់ទ្រង់មាន់ដែលមានបណ្ដោយ ៤ម៉ែត្រ ។ ទទឹង ២,៨ម៉ែត្រ និងកំពស់ ១,៨ម៉ែត្រ ដំបូលប្រក់ស្លឹកត្នោត ៥០ក្បាល និងកូនចំនួន ២០ក្បាល មាន់ជំទង់ចំនួន ៥០ក្បាល និងកូនមាន់បានចំនួន ១២០ក្បាល ។

## ខ. ពូជមាន់

លោកពូ រ៉ន សារ៉ែម បានមានប្រសាសន៍ថា ការជ្រើសរើសពូជមាន់មានសារៈសំខាន់ណាស់ក្នុងការយកមកចិញ្ចឹម ហេតុដូចនេះគាត់បានសម្រេចចិត្តទិញពូជមាន់កាត់បីសាសន៍ (ខ្មែរ វៀតណាម និងម៉ាឡេ) ពីព្រោះមានមាឌធំ រោមច្រើន ធន់នឹងជម្ងឺ ជាពិសេសចិញ្ចឹមឆាប់ធំធាត់លឿន ។

## គ. ការថែទាំ និងអនាម័យ

គាត់បានបោសសំអាតទ្រុងជាប្រចាំថ្ងៃ រីឯស្នូកទឹក ស្នូកចំណីលាងរាល់ពេលមុនដាក់ទឹក និងចំណី ។ ជារៀងរាល់ ១ ឬ ៣ខែម្ដង គាត់បាញ់ថ្នាំធីអេចហ្វ៊រ ឬបាចកំបោរសនៅក្នុងទ្រុង និងបរិវេណភូមិទាំងមូល ដើម្បីសម្លាប់មេរោគ ។

## ឃ. ការផ្ដល់ចំណី



ចំពោះកូនមាន់ទើបតែញាស់រហូតដល់ ២៥ថ្ងៃ គាត់ផ្ដល់ចំណី ១ថ្ងៃ ៣ដង ដូចជា ចុងអង្ករ កន្ទក់ម៉ដ្ឋ និងមានចំណីក្រុមហ៊ុនខ្លះ ចំពោះទឹកវិញលាយជាមួយទឹកអូរីលីត្រ

ចំពោះមាន់ចាប់ពី ២៦ថ្ងៃឡើងទៅគាត់ផ្ដល់ចំណី ១ថ្ងៃ

២ដង ដូចជា ចុងអង្គរ ស្រូវត្រាំ ត្រកួន ស្លឹកដំឡូង ។

## ង. វិធីផ្សំចំណី

ផ្សំចំណីសម្រាប់មាន់ចំនួន ៥០ក្បាល យើងត្រូវការ:

- ចុងអង្គរចំនួន ១គីឡូក្រាម និងកន្ទក់ ចំនួន ១,៥គីឡូក្រាម
- ចកបាយទា ចំនួន ១គីឡូក្រាម និងស្លឹកដំឡូងចំនួន កន្លះគីឡូក្រាម
- ត្រកួនចំនួន ១គីឡូក្រាម និងស្រូវត្រាំចំនួន ១គីឡូក្រាម

សំគាល់: ស្លឹកដំឡូង និងត្រកួនត្រូវហាន់ឲ្យតូចៗ រួចបុកបញ្ចូលគ្នាជាមួយវត្ថុធាតុផ្សំផ្សេងៗទៀត ។ ចំពោះចំណីផ្សំនេះផ្តល់ឲ្យ ១ថ្ងៃម្តង ក្នុងរយ:ពេល ៣ថ្ងៃ ឬ ១សប្តាហ៍ សម្រាប់មាន់មានអាយុពី ២៦ ថ្ងៃឡើងទៅ ។ សម្រាប់មេមាន់ពង គឺការផ្សំដូចខាងលើដែរ តែថែមសំបកខ្ចៅខ្ចង និងគ្រា>ប់ខ្សាច់ ធន់កណ្តាលបន្តិចផង ។

## ច. ជម្ងឺ និងការការពារ

គាត់បានមានប្រសាសន៍ថា សម្រាប់វិធានការណ៍ការពាររបស់គាត់ គឺគាត់បានយកសំបកស្តៅ សំបកគ សំបកទុំទេស និងគល់ស្លឹកគ្រៃដាក់ផ្សំចូលគ្នាដាំឲ្យពុះ រួចទុកឲ្យត្រជាក់ដាក់ឲ្យមាន់ផឹកជា រៀងរាល់ថ្ងៃ ។ ម្យ៉ាងទៀតគាត់បានយកចុងអង្គរ ប៉ាក់សេតាម៉ុល និងថ្នាំ ធីធីអេស ដាក់លាយចូលគ្នា ឲ្យមាន់ស៊ី ១សប្តាហ៍ ១ដង ។ ជាពិសេសាកត់បានដាក់ថ្នាំទម្លាក់ព្រូន ១ខែម្តងជាប្រចាំ ។

## ឆ. ចំណាយ-ចំណូលពីផលិតកម្មមាន់

ក្នុងរយ:ពេល ១ឆ្នាំ លោកពូបានលក់មាន់ជាបន្តបន្ទាប់បានប្រាក់សរុប ២.៥៩៩.០០០រៀល ហើយ មាន់នៅសល់ទាំងតូច និងធំប្រមាណជាង ១៥០ក្បាល បើគិតជាទឹកប្រាក់ប្រមាណជាង ១លាន រៀលទៀត ។ ដូច្នេះបើសរុបចំណូលទាំងអស់បានប្រមាណជាង ៣លានរៀល ។ ចំពោះ ការចំណាយទៅលើចំណី និងវិធានការណ៍ការពារអស់ចំនួន ៨០៥.០០០រៀល ។

បើធ្វើការវិភាគរកចំណេញខាតបានឲ្យឃើញថាគាត់ទទួលផលចំណេញប្រមាណជាង ២លានរៀល តែមិនបានគិតពីការសាងសង់ទ្រុង និងកំលាំងពលកម្មទេ ។

## ជ. ចំណាប់អារម្មណ៍

គាត់បានមានប្រសាសន៍ទាំងទឹកមុខញញឹមញញែមថា ចាប់តាំងពីគម្រោងដៃគូរបស់អង្គការអ្នកក្សេត្រសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែនបានផ្តល់បច្ចេកទេសពីការចិញ្ចឹមមាន់មក បានធ្វើឲ្យក្រុមគ្រួសាររបស់គាត់រកប្រាក់ចំណូលបន្ថែម បានយ៉ាងងាយស្រួលជាងមុន ដែលធ្វើឲ្យគ្រួសារគាត់អាចផ្គត់ផ្គង់ការសិក្សារបស់កូនគាត់ទាំង ២នាក់ បានអាចទិញសំលៀកបំពាក់សម្រាប់គ្រួសារខ្លះៗ ចូលបុណ្យ ឬចងដៃការ ដោយមិនចាំបាច់លក់ស្រូវ ដូចពីពេលមុន ។ គាត់បានផ្តាំផ្ញើថា សូមចាប់អារម្មណ៍លើការចិញ្ចឹមមាន់ ពីព្រោះវាជាមុខរបរមួយដែលប្រាក់ហូរចូលយ៉ាងច្រើនដោយមិនដឹងខ្លួន ដូចសុភាសិតខ្មែរពោលថា 'តត់ៗពេញបំពង់' ។

**មាង សារឿន**

ទូរស័ព្ទទំនាក់ទំនងពត៌មានបន្ថែម: ០១២ ៨២០ ៩៥៩

(ដកស្រង់ចេញពីទស្សនាវដ្តីកសិករ របស់អង្គការសេដាក)